**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ១២២៩៤ អពដ

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

## ស្តីពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំជាប់ពន្ធ ២០១៣

អនុលោមតាមមាត្រា ៥ និងមាត្រា ២៩ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ អគ្គនាយកដ្ឋានពន្ធដារមានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក-លោកស្រី ជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ទាំងអស់ជ្រាបអំពីកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ២០១៣ ដូចខាងក្រោម:

១-សហគ្រាសដែលប្រើប្រាស់ឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន (០១ ខែមករា ដល់ ៣១ ខែធ្នូ) ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ សម្រាប់ការិយបរិច្ឆេទឆ្នាំ ២០១៣ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៤ នៅរដ្ឋបាលសារពើពន្ធដែលមានសមត្ថកិច្ចគ្រប់គ្រងប្រមូលពន្ធលើសហគ្រាសនោះ។

២-សហគ្រាសដែលត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឆ្នាំជាប់ពន្ធខុសពីឆ្នាំប្រតិទិន ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំយ៉ាងយឺតបំផុតក្នុងរយៈពេល ៣ ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធ។

៣-សហគ្រាសដែលមានសាខាច្រើន ត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលបានមកពីលទ្ធផលសរុបរួមបញ្ចូលគ្នារបស់គ្រឹះស្ថានជាគោលដើម និងគ្រប់សាខាទាំងអស់ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍លទ្ធផលចំណេញ-ខាតរបស់សាខានីមួយៗ។ គ្រឹះស្ថានដែលជាសាខានីមួយៗ ត្រូវប្រកាសលទ្ធផលចំណេញ-ខាតសាខារបស់ខ្លួនតាមគំរូលិខិតប្រកាសពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងដាក់ជូនរដ្ឋបាលសារពើពន្ធនៅទីកន្លែងដែលសាខាជាប់ទាក់ទិននីមួយៗតាំងនៅ។

៤-សហគ្រាសដែលអនុវត្តគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គលគ) ច្រើន ឬអនុវត្តគម្រោងដទៃទៀតច្រើនដែលជាគម្រោង គលគ ផង និងមិនមែនជា គលគ ផង ហើយដែលទទួលបានការលើកលែងពន្ធលើប្រាក់ចំណេញខុសគ្នា ឬត្រូវជាប់ពន្ធលើប្រាក់ចំណេញតាមអត្រាខុសៗគ្នា ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដូចមានចែងក្នុងចំណុច ១ ដល់ ៣ ខាងលើ និងត្រូវអនុវត្តតាមការណែនាំបន្ថែមដោយឡែករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៥-ចំពោះតំណាងអ្នកជាប់ពន្ធដែលទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយរដ្ឋបាលសារពើពន្ធ និងដាក់លិខិតប្រកាសពន្ធប្រចាំខែ ប្រចាំឆ្នាំ ជំនួសមុខឲ្យអ្នកជាប់ពន្ធ ត្រូវមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរពីអ្នកជាប់ពន្ធដូចមានចែងក្នុងមាត្រា ១០៦ នៃច្បាប់ស្តីពីសារពើពន្ធ។

**៦-គ្រប់សហគ្រាសទាំងអស់ដែលមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ ត្រូវភ្ជាប់មកជាមួយនូវ តារាងតុល្យការ គណនីលទ្ធផល និងតារាងប្រតិបត្តិការជាមួយបុគ្គលទាក់ទិនដូចមានក្នុងតារាងភ្ជាប់មកជាមួយ។**

ក្នុងករណីលោក-លោកស្រី មានចម្ងល់ផ្សេងៗ សូមទាក់ទងជាមួយការិយាល័យចុះបញ្ជី និងសេវាអ្នកជាប់ពន្ធនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សាខាពន្ធដារខណ្ឌ និងសាខាពន្ធដារខេត្តដែលទាក់ទិន។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹម និងជឿជាក់ថា លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិកររបស់សហគ្រាសពិតជាយកចិត្តទុកដាក់អញ្ជើញមកដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណេញតាមច្បាប់កំណត់។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

ឈ្មោះក្រុមហ៊ុន:............................................................ លេខអតប:................................

# តារាងប្រតិបត្តិការជាមួយបុគ្គលទាក់ទិន

ការិយបរិច្ឆេទ:...................................

## ក.ប្រតិបត្តិការលក់ និងការឲ្យខ្ចីផ្សេងៗ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទប្រតិបត្តិការ | ចំនួនទឹកប្រាក់ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |

## ខ.ប្រតិបត្តិការទិញ និងកម្ចីផ្សេងៗ

| ល.រ | ឈ្មោះក្រុមហ៊ុន | ប្រភេទប្រតិបត្តិការ | ចំនួនទឹកប្រាក់ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ៤ | | | |
| ៥ | | | |
| | | | |

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ ........ ឆ្នាំ.............

ហត្ថលេខា និងត្រា ប្រធានក្រុមហ៊ុន

សំគាល់:

យោងមាត្រា ៣ ថ្មី កថាខ័ណ្ឌទី១០ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ពាក្យថា " បុគ្គលទាន់ទិន " សំដៅដល់:

ក.សមាជិកណាម្នាក់ក្នុងគ្រួសារអ្នកជាប់ពន្ធ

ខ.សហគ្រាសដែលគ្រប់គ្រងលើអ្នកជាប់ពន្ធ ឬសហគ្រាសត្រូវបានអ្នកជាប់ពន្ធគ្រប់គ្រង ឬក៏សហគ្រាសនោះ និងអ្នកជាប់ពន្ធស្ថិតនៅក្រោមការគ្រប់គ្រងរួមគ្នា។ ពាក្យថា " គ្រប់គ្រង " មានន័យថាមាន កម្មសិទ្ធិចាប់ពី ៥១ ភាគរយ ឡើងទៅលើតម្លៃ ឬសិទ្ធិបោះឆ្នោតនៃភាគកម្មនៅក្នុងដើមទុនផ្ទាល់របស់សហគ្រាស។